# **បណ្ដឹងទាលិខិតសុំដីកាបញ្ជាសំរាប់ការពារ**(គ្រប់សំណុំរឿង)
# PETITION FOR ORDER FOR PROTECTION (All Cases)

ឯកសារនេះសំរាប់សុំឲ្យតុលាការការពារអ្នក និង/ឬកូនៗរបស់អ្នក ពីអំពើហឹង្សាគ្រួសារ ។ ក្រដាសពាក្យនេះផ្ដល់ឲ្យចៅក្រម នូវពត៌មានអំពី មូលហេតុដែលអ្នកត្រូវការដីកាបញ្ជាការពារ ។ ដើម្បីឲ្យមានលក្ខណសម្បត្តិដល់ដីកាបញ្ជានេះ អ្នកមិនចាំបាច់មាន គ្រោះថ្នាក់ រូបរាងកាយទេ ។ បើអ្នកអាចប្រាប់តុលាការ នូវមូលហេតុដែលអ្នកភ័យខ្លាច ថាអ្នកនឹងត្រូវមានការឈឺចាប់,អ្នកប្រហែល ជាអាចទទួលដីកាបញ្ជានេះបាន ។

ក្រដាសពាក្យនេះ អាចប្រើដើម្បីសុំនូវកិច្ចការពារបានទាំងពីរយ៉ាង គឺការពារភ្លាមៗជាបណ្ដោះអាសន្ន **និង** ការពារបន្ដទៅ ទៀត ។ បើអ្នកត្រូវការកិច្ចការពារភ្លាមៗ,ហើយតុលាការរកឃើញថា នឹងមានភាពអាសន្ន,តុលាការអាចចេញដីកាបញ្ជាបណ្ដោះ អាសន្នភ្លាមៗ ដែលនឹងបន្ដរហូតដល់ពេលសវនាការ,តាមធម្មតា,ក្នុងរវាង១៤ថ្ងៃ ។ នៅពេលសវនាការនោះ,តុលាការ នឹងសំរេចថា តើគួរបន្ដដីកាបញ្ជាការពារ ឬយ៉ាងណា ។ ជនឆ្លើយតប មានសិទ្ធិនិងចូលរួមក្នុងសវនាការ នេះបាន ។ បើអ្នកត្រូវការកិច្ចការពារ ទាំងពីរយ៉ាង គឺការពារជាបណ្ដោះអាសន្នភ្លាមៗនិងការពារបន្ដទៅទៀត,អ្នកចាំបាច់ត្រូវតែគូស ហើយនិងបំពេញក្រដាសពាក្យនេះ ទាំងពីរភាគ ត្រង់ទំព័រ២ និង៣នៅពេលជាមួយគ្នា ។

## **ពត៌មានដំបូង** (ទំព័រ១)

ចូរបំពេញឈ្មោះអ្នក ជា"បណ្ដឹងទាការជន "។ ជនដែលអ្នកចង់ឲ្យតុលាការការពារ គឺ(ចុងចោទ) ។ ចូរបំពេញឈ្មោះជនឆ្លើយតប ។

## **តើនរណាត្រូវការកិច្ចការពារ**(សំណួរទី១)

តុលាការត្រូវស្គាល់ជនដែលត្រូវការកិច្ចការពារ ។ ចូរគូសប្រអប់ទីមួយមុនដំបូង បើអ្នកត្រូវការកិច្ចការពារ ។ ចូរគូសប្រអប់ទីពីរ បើជនណាមួយក្នុងគ្រួសារអ្នក ឬសមាជិកគ្រួសារអ្នក ត្រូវការកិច្ចការពារ ។ អ្នកអាចគូសប្រអប់ទាំងពីរបាន ។

## **លំនៅដ្ឋាន** (សំណួរទី២)

តុលាការត្រូវការដឹងទីកន្លែងអ្នករស់នៅ ដើម្បីធ្វើសេចក្ដីសំរេចមើល ថាតើគួរចេញដីកាបញ្ជាការពារឬយ៉ាងណា ។ ចូរគូសប្រអប់**មួយ** ចំណោមប្រអប់ទាំងនេះ ដើម្បីប្រាប់តុលាការឲ្យដឹង នូវទីកន្លែងអ្នកកំពុងរស់នៅ ។

## **អាយុ**(សំណួរទី៣)

តុលាការត្រូវការដឹងអាយុនៃភាគីទាំងពីរ ។ ចូរគូសប្រអប់មួយ ចំណោមប្រអប់ទាំងនេះ សំរាប់ប្រាប់អាយុរបស់អ្នក ។ ចូរគូស ប្រអប់មួយចំណោមប្រអប់ទាំងនេះ ដើម្បីប្រាប់អាយុរបស់ចុងចោទ ។

## **ទំនាក់ទំនងគ្នា**(សំណួរទី៤)

តុលាការត្រូវដឹងនូវទំនាក់ទំនងគ្នា រវាងអ្នក ហើយនិងជនឆ្លើយតប ។ ចូរគូសប្រអប់ទាំងអស់ ដើម្បីរៀបរាប់នូវស្ថានភាពរបស់អ្នក ។ បើអ្នកធ្វើបណ្ដឹងទាការ ក្នុងនាមនៃក្មេងក្រោមអាយុ,ទំនាក់ទំនងក្មេងក្រោមអាយុ ទៅនិងចុងចោទ ត្រូវរៀបរាប់ត្រង់សំណួរលេខ៥ ។

## **អត្តសញ្ញាណនៃក្មេងក្រោមអាយុ**(សំណួរទី៥)

បើមិនមានក្មេងចូលរួមទេ,ចូរគូសប្រអប់បង្ហាញថា"មិនមានក្មេងរួមទេ" ។ ប្រសិនបើមានក្មេង,តុលាការត្រូវការដឹងអំពីក្មេងនៅក្នុង សំណុំរឿងនេះ ។ ចូរចុះឈ្មោះក្មេងនិមួយៗ,អាយុ,ពូជសាសន៍,ហើយនិងភេទ ។ ចូរបំពេញប្រាប់អំពីក្មេងនេះមានទំនាក់ទំនងដូចម្ដេចទៅនិង អ្នក(ដូចជាត្រូវជាកូនប្រុស) ។ ចូរបំពេញប្រាប់អំពីក្មេងនេះ មានទំនាក់ទំនងទៅនិងចុងចោទដូចម្ដេច ។ ចូរបំពេញប្រាប់ថា ក្មេងនៅ ជាមួយអ្នកណា(ដូចជា,នៅជាមួយខ្ញុំ,យាយ-តា,ចុងចោទជាដើម)។

**<u>សំណុំរឿងតុលាការ</u>**(សំណួរទី៦)

នេះប្រហែលមិនមែនជាទំរង់ការតុលាការ លើកទីមួយទេ ដែលមានទាក់ទងនិងរឿងអ្នក,ឬក្មេងក្រោមអាយុ ហើយនិងចុងចោទ ។ តុលាការ ត្រូវការដឹងអំពីសំណុំរឿងដទៃ ឬដីកាបញ្ជាហាមឃាត់ដទៃទៀត ដីកាការពារឬដីកាបញ្ជាមិនឲ្យទាក់ទង ដើម្បីកុំឲ្យតុលាការ ចេញដីកាបញ្ជា ដែលបណ្តាលឲ្យមានការប្រឆាំង ជាមួយនិងដីកាបញ្ជាពីតុលាការផ្សេងទៀត ។

ប្រសិនបើមានសំណុំរឿងដទៃ ឬមានដីកាបញ្ជាហាមឃាត់,ការពារ,ឬបញ្ជាមិនឲ្យទាក់ទងអ្នក,ឬក្មេងក្រោមអាយុ,ហើយនិងជនឆ្លើយតប,ត្រូវចុះសារបានសំណុំរឿង(ឈ្មោះភាគី),លេខសំណុំរឿង(បើអ្នកដឹង),ហើយនិងតុលាការ(សង្កាត់,តុលាការក្រុង, ឬតុលាការជាន់ខ្ពស់)ហើយនិងខោនធី នៅត្រង់ជួរដែលផ្តល់ឲ្យ ។

## **សំណើសុំកិច្ចការពារ**(ទំព័រ២)

ទាំងនេះគឺជាបែបនៃកិច្ចការពារផ្សេងៗគ្នា ដែលប្រហែលជាអ្នកត្រូវការ ។ ដើម្បីស្នើសុំឲ្យតុលាការចេញ ដីកាបញ្ជាកិច្ចការពារបណ្តោះអាសន្ន ដែលអាចប្រើភ្លាមៗបាន ហើយដែលនិងនៅប្រើបាន រហូតដល់ថ្ងៃសវនាការ សំរាប់បន្តដីកាបញ្ជាឲ្យការពារ,ចូរគូសឲ្យបានគ្រប់ទាំងអស់ ដែលអ្នកត្រូវការ **នៅត្រង់ជួរខាងឆ្វេងលើទំព័រ២ និងទំព័រ៣** ។ ដើម្បីស្នើសុំ តុលាការឲ្យបន្តកិច្ចការពារ(ពេញ),ហើយដែលតុលាការប្រហែលជាចេញឲ្យនៅពេលចប់សវនាការ,ចូរគូសឲ្យបានគ្រប់ទាំងអស់ តាមដែលអ្នកត្រូវការ **នៅត្រង់ជួរទីពីរលើទំព័រ២ និងទំព័រ៣** ។

1. ចំណុចទីមួយ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ទៅឲ្យជនឆ្លើយតបថា មិនត្រូវធ្វើឲ្យមានគ្រោះថ្នាក់ដល់រាងកាយ,ឈ្លបចាប់,ឬប្រើពាក្យសំដីអសុរោះទៅលើអ្នក និង/ឬក្មេងៗដែលអ្នកចុះឈ្មោះនេះ ។

    a. ចូរគូសប្រអប់"ខ្ញុំ" បើអ្នកត្រូវការកិច្ចការពារ ។
    b. ចូរគូស"ក្មេងក្រោមអាយុ ដែលមានឈ្មោះ នៅត្រង់អត្ថបទលេខ៥ខាងលើ" បើក្មេង <u>ទាំអស់</u> ដែលអ្នកបានចុះឈ្មោះនេះ ត្រូវការកិច្ចការពារ ។
    c. ចូរគូស"ត្រឹមតែក្មេងក្រោមអាយុប៉ុណ្ណោះ" បើមានក្មេងខ្លះត្រូវការកិច្ចការពារ ។ បើអ្នកគូសប្រអប់នេះ,ចូរចុះឈ្មោះក្មេង ដែលត្រូវការកិច្ចការពារ ឲ្យបានប្រាកដ ។

    សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

2. ចំណុចទីពីរ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ទៅឲ្យជនឆ្លើយតបថា មិនត្រូវទាក់ទងអ្នក និង/ឬក្មេងៗដែលអ្នកចុះឈ្មោះ។

    ចំពោះកិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ ចំពោះកិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

3. ចំណុចទីបី ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ឲ្យដកជនឆ្លើយតប ចេញពីផ្ទះរបស់អ្នក,កន្លែងធ្វើការ,សាលារៀន ឬកន្លែងមើលក្មេងក្រោមអាយុ ឬសាលារៀន ។ ប្រសិនបើមានកន្លែងខ្លះៗ ដែលអ្នកចង់បញ្ចូល,ចូរបញ្ចូលត្រង់ប្រអបមួយហៅថា "ផ្សេងៗ" ។ អ្នកមានសិទ្ធិរក្សាអាសយដ្ឋានរបស់អ្នកជាអាថ៌កំបាំង(សម្ងាត់)បាន ។ ខ័សន្យាហាមឃាត់ នៅត្រង់ដីកាបញ្ជាបណ្តោះអាសន្ន ហើយនិងនៅត្រង់ដីកបញ្ជាទាំងស្រុង មានកន្លែងចំហរទុកឲ្យអ្នកសរសេរ ទីលំនៅបច្ចុប្បន្នរបស់អ្នក ។ គេមិន តម្រូវឲ្យអ្នកសរសេរអាសយដ្ឋានទីលំនៅរបស់អ្នកឡើយ ប្រសិនបើអ្នកមានកង្វល់អំពីសន្តិសុខ ឬការលួចអត្តសញ្ញាណរបស់ អ្នក ។ ថ្វីបើយ៉ាងនេះក៏ដោយ,ការបង្ខំឲ្យធ្វើតាមដីកាបញ្ជា ប្រហែលជាងាយជាង ប្រសិនបើអ្នកបានបញ្ចូលអាសយដ្ឋានរបស់អ្នករួមផង ។ ប្រសិនបើអ្នកសំរេចថា បញ្ចូលអាយដ្ឋានរបស់អ្នក,សូមចុះអាសយដ្ឋានឲ្យបានគ្រប់ រួមទាំងឈ្មោះក្រុងផង ។

    សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

4. ចំណុចទីបួន ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ទៅឲ្យចុងចោទថា ត្រូវចេញពីផ្ទះ ដែលអ្នកទាំងពីរ បានចែកគ្នានៅ ហើយប្រគល់សិទ្ធិទាំងស្រុង ឲ្យអ្នករស់នៅនិងផ្ទះនោះ ។ អ្នកមានសិទ្ធិរក្សាអាសយដ្ឋានេះ ជាអាថ៌កំបាំង"សម្ងាត់"។ ខសន្យាហាមឃាត់ ត្រង់ដីកាបញ្ជាបណ្តោះអាសន្ន ហើយនិងត្រង់ដីកាបញ្ជាទាំងស្រុងនេះ មានចន្លោះចំហរទុកឲ្យ អ្នកសរសេរ អាសយដ្ឋានរបស់អ្នក ។ គេមិនតម្រូវឲ្យអ្នកសរសេរអាសយដ្ឋានទីលំនៅរបស់អ្នកឡើយ ប្រសិនបើអ្នក មានកង្វល់អំពីសន្តិសុខ ឬការលួចអត្តសញ្ញាណរបស់អ្នក ។ ថ្វីបើយ៉ាងនេះក៏ដោយ,ការបង្ខំឲ្យធ្វើតាមដីកាបញ្ជា ប្រហែលជាងាយជាង ប្រសិនបើអ្នកបានបញ្ចូលអាសយដ្ឋានរបស់អ្នករួមផង ។ ប្រសិនបើអ្នកសំរេចថាបញ្ចូល អាយដ្ឋានរបស់អ្នក,សូមចុះអាសយដ្ឋានឲ្យបានគ្រប់ រួមទាំងឈ្មោះក្រុងផង ។

សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

5. ចំណុចទីប្រាំ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ហាមមិនឲ្យជនឆ្លើយតបមកកាន់ផ្ទះ ឬរស់នៅចម្ងាយពីផ្ទះដោយចេតនា ចម្ងាយកំណត់(ដូចជា, ១០០ហ្វីត,២ប្លុក))ពីផ្ទះរបស់អ្នក,កន្លែងធ្វើការឬសាលារៀន;ឬកន្លែងមើលក្មេងក្រោមអាយុ ឬសាលារៀន របស់វា ។ ប្រសិនបើមានកន្លែងខ្លះៗ ដែលអ្នកចង់បញ្ចូល,ចូរបញ្ចូលត្រង់ប្រអបមួយហៅថា"ផ្សេងៗ" ។

សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

6. ចំណុចទីប្រាំមួយ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ប្រគល់ឲ្យអ្នកមានសិទ្ធិគ្រប់គ្រងកម្មសិទ្ធិពិសេសផ្ទាល់ខ្លួន ។ ចូរចុះ ឈ្មោះរបស់ផ្ទាល់ខ្លួន ។ (កម្មសិទ្ធិផ្ទាល់ខ្លួនពិសេសៗ)មានន័យថា របស់ទាំងនោះ គឺជាវត្ថុចាំបាច់សំរាប់សុខភាពបន្ទាន់ របស់បុគ្គលនោះ,សុខុមាលភាព ហើយនឹងជីវភាពរស់នៅជាដើម ។ (កម្មសិទ្ធិផ្ទាល់ខ្លួនពិសេសៗ)មាន,ប៉ុន្តែមិនកំរិតដល់ សំលៀកបំពាក់,គ្រែទារក,គ្រែដេក,ឯកសារ,ថ្នាំពេទ្យ,ហើយនិងរបស់អនាម័យផ្ទាល់ខ្លួន ។ (RCW 26.50.010(7)) ។

សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

7. ចំណុចទីប្រាំពីរ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ឲ្យអ្នកមានសិទ្ធិប្រើរថយន្ត(ដូចជា,1994 Ford Taurus ពណ៌ខៀវ, License Number XYZ123) ។

សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

8. ចំណុចទីប្រាំបី,ផ្សេងៗ"កន្លែងដែលអ្នកត្រូវចុះឈ្មោះអ្វីៗដទៃទៀត ដែលមិនបានចុះនៅត្រង់ចំណុចខាងលើ ។

សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ ចំពោះកិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

9. ចំណុចទីប្រាំបួន ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ឲ្យជនឆ្លើយតប ទទួលការព្យាបាល ឬឱវាទណែនាំ ។

សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។ (ចំណុចនេះ មិនមានលទ្ធភាព នៅត្រង់ដីកាបញ្ជាបណ្តោះអាសន្នឡើយ) ។

10. ចំណុចទីដប់ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ទៅឲ្យចុងចោទ ចេញថ្លៃឈ្នួល និងតម្លៃផ្សេងៗ សំរាប់សកម្មភាពនេះ ។ (ថ្លៃឈ្នួលនិងតម្លៃផ្សេងៗមានថ្លៃឈ្នួលតុលាការ,ថ្លៃឈ្នួលការបំរើផ្សេងៗហើយនិងតម្លៃមេធាវីដោយសមរម្យ) ។

សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។ (ចំណុចនេះ មិនមានលទ្ធភាព នៅត្រង់ដីកាបញ្ជាបណ្តោះអាសន្នឡើយ) ។

11. ចំណុចទីដប់មួយ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ឲ្យបានជាងមួយឆ្នាំ ។ ចូរគូសតែត្រង់ប្រអប់នេះប៉ុណ្ណោះ ប្រសិនបើមានមូលហេតុ ដែលគួរឲ្យជឿថា ជនឆ្លើយតប នៅបន្តហិង្សាគ្រួសារ ទល់នឹងអ្នក បើដីកាបញ្ជាត្រូវចប់ក្នុងរយៈមួយឆ្នាំ ។

សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។ (ចំណុចនេះ មិនមានលទ្ធភាព នៅត្រង់ដីកាបញ្ជាបណ្តោះអាសន្នឡើយ) ។

**បើមិនមានក្មេងក្រោមអាយុចូលរួមផងទេ,ចូរកុំគូសសំណួរ១២,១៣ និង១៤ ។**

**បើអ្នកស្នើសុំកិច្ចការពារ រួមចូលនិងក្មេងក្រោមអាយុផង,ចូរឆ្លើយសំណួរ១២,១៣ និង១៤ ។**

12. ចំណុចទីដប់ពីរ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ឲ្យអ្នកថែទាំ,អាណាព្យាបាល និងគ្រប់គ្រងក្មេងជាបណ្តោះអាសន្ននៃក្មេងដែលអ្នកចុះ ឈ្មោះ ។

សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

13. ចំណុចទីដប់បី ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា មិនឲ្យជនឆ្លើយតបធ្វើអន្តរាគមន៍ លើអាណាព្យាបាលភាពនៃក្មេងៗដែលអ្នកចុះឈ្មោះ ។

សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

14. ចំណុចទីដប់បួន ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ទៅឲ្យជនឆ្លើយតបថា មិនត្រូវយកក្មេងដែលមានចុះឈ្មោះទាំងនេះចេញពីរដ្ឋ ។

សំរាប់កិច្ចការពារជាបណ្តោះអាសន្ន,ចូរគូសត្រង់ជួរខាងឆ្វេងបំផុត ។ សំរាប់កិច្ចការពារបន្ត,ចូរគូសជួរទីពីរ ។

## ការស្នើសុំជំនួយពិសេស ពីទីភ្នាក់ងារក្រសួងមានសមត្ថកិច្ច

អ្នកប្រហែលជាត្រូវការជំនួយពិសេសពីប៉ូលិស ។ ចូរគូសគ្រប់ទាំងអស់ ដែលអ្នកគិតថា អ្នកត្រូវការឲ្យប៉ូលិសជួយអ្នក ឲ្យបានអ្វីផ្សេងៗ ។

1. ចំណុចទីមួយ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ឲ្យប៉ូលិសជួយអ្នក ឲ្យបានចូលទៅផ្ទះអ្នកវិញ ។

2. ចំណុចទីពីរ ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ឲ្យប៉ូលិសជួយអ្នក ឲ្យបានប្រើរថយន្ត ។

3. ចំណុចទីបី ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ឲ្យប៉ូលិសជួយអ្នក ឲ្យបានរបស់កម្មសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកវិញ ។ ចូរគូសត្រង់ប្រអប់ដែលអ្នកចង់ឲ្យប៉ូលិសជួយ ឲ្យបានរបស់ជាកម្មសិទ្ធិរបស់អ្នក ពីជនដែលបានចែកទីលំនៅ,ពីទីលំនៅរបស់ជនឆ្លើយតប ឬពីកន្លែងដទៃទៀត ។

4. ចំណុចទីបួន ស្នើសុំឲ្យតុលាការចេញដីកាបញ្ជា ឲ្យប៉ូលីសជួយអ្នក ឲ្យបានគ្រប់គ្រងក្មេង ដែលអ្នកចុះឈ្មោះ ។ (មានភាពតឹងតែងច្រើន ដែលក្រសួងមានសមត្ថកិច្ចអាចធ្វើបាន ។ ចូរទាក់ទងទីភ្នាក់ងារក្រសួងមានសមត្ថកិច្ចតំបន់អ្នក) ។

5. ចំណុចចុងក្រោយបង្អស់ អនុញ្ញាតឲ្យអ្នកស្នើសុំជំនួយ ដែលអ្នកប្រហែលជាត្រូវការ ពីប៉ូលីស ។

## សេចក្តីបញ្ជាក់នៃបដ្ឋទាការ

សេចក្តីបញ្ជាក់នៃបដ្ឋទាការជន គឺត្រូវពណ៌នាប្រាប់តុលាការ នូវមូលហេតុដែលអ្នកត្រូវការដីកាបញ្ជាតុលាការ ។ ឯកសារនេះ នឹងត្រូវគេទុកនៅក្នុងសំណុំរឿងតុលាការ ដែលជាឯកសារសាធារណៈ ហើយនិងចែកឲ្យទៅជនឆ្លើយតបផង ។ បើអ្នកមិនបានបញ្ចូលឧប្បត្តិហេតុពិសេស។ នៃហឹង្សាគ្រួសារ នៅក្នុងសេចក្តីបញ្ជាក់របស់អ្នកទេ,អ្នកប្រហែលជាមិនមានឱកាស ដើម្បីនិយាយប្រាប់តុលាការបានសព្វគ្រប់ឡើយ នៅពេលសវនាការ ។

ជាដំបូង ចូរអានអត្ថន័យនៃហឹង្សាគ្រួសារ នៅត្រង់ប្រអប់លើសេចក្តីបញ្ជាក់ ។ បន្ទាប់មក,អានសេចក្តីបញ្ជាក់ជាបន្តបន្ទាប់មកទៀត,មុននិងអ្នកចាប់ផ្តើមសរសេរ ។ ក្នុងនោះមានប្រាប់ពត៌មានយ៉ាងឆាប់ជាច្រើន ដើម្បីជួយគំនិតរបស់អ្នក ។

ចូររៀបរាប់ឲ្យបានច្បាស់ នូវរឿងរ៉ាវ ដែលបានកើតឡើង នៅពេលអ្នកមានការគំរាមកំហែង ឬពេលទទួលការឈឺចាប់ ។ ពត៌មានពិស្តារ ដែលអ្នកអាចផ្តល់បាន ដូចជាខែ/ថ្ងៃ/ឆ្នាំ និងពេលម៉ោងជាដើម,អាចបានជាជំនួយច្រើន សំរាប់ចៅក្រម ។ ចូរសរសេរចុះឧទាហរណ៍ ឲ្យបានច្រើន ប្រសិនបើអាច ។ ប្រសិនបើមានភាពអាសន្ន,ចូរអធិប្បាយនូវមូលហេតុនោះ សំរាប់ឲ្យតុលាការអាចចេញដីកាបញ្ជាបណ្តោះអាសន្នភ្លាម។ នៅមុនពេលសវនាការ ។ បន្ថែមទៅនិងពត៌មាន ដែលបានស្នើនៅក្នុងសេចក្តីបញ្ជាក់; អ្នកប្រហែលជាចង់បញ្ចូលៈ

- បើជនឆ្លើយតប បានធ្វើឲ្យអ្នកដទៃឈឺចាប់;
- បើជនឆ្លើយតប ត្រូវប៉ូលីសចាប់ទៅឃុំឃាំង;
- បើប៉ូលីស បានឆ្លើយថា ចាប់មិនទាន់បាននៅឡើយ;
- បើគេបានឈ្លបចាប់អ្នក,ចូររៀបរាប់ពីរបៀបនៃការឈ្លបចាប់;

ឧទាហរណ៍:

អ្នកគួរនិយាយថា" នៅថ្ងៃសៅរ៍,ទី១២ខែមករា,វេលាម៉ោង២:០០ព្រឹក,Terry បានទះកំភ្លៀងខ្ញុំ" ប្រសើរជាង "នៅថ្ងៃសៅរ៍ Terry បានវាយខ្ញុំ" ។

អ្នកគួរត្រូវនិយាយថា,(Terry បានគំរាមថា នឹងសម្លាប់ខ្ញុំ បើខ្ញុំចេញពីផ្ទះ)។ គាត់បាននិយាយថា បើអ្នកចេញ,ខ្ញុំនឹងសម្លាប់អ្នកឯង),ប្រសើរជាងនិយាយថា(Terry បានគំរាមកំហែងខ្ញុំ) ។

ចូរសាកល្បងប្រើពាក្យឲ្យដូចជនឆ្លើយតបបាននិយាយ ពេលគេបានគំរាមកំហែងដោយដោយធ្វើទុក្ខទោស[រាងកាយ] ។

ប្រសិនបើពត៌មានទាំងប៉ុន្មានខាងលើ មិនមានទាក់ទងដល់អ្នកទេ,ចូរសរសេរថា(មិនទាក់ទង)នៅត្រង់ផ្នែកនេះ ។

ចូរជ្រើសយកប្រអប់ដែលសមរម្យ បើមានទាក់ទងនិងសារធាតុ(គ្រឿងញៀន) ។

ពេលអ្នកបានបញ្ចប់នូវសេចក្តីបញ្ជាក់របស់អ្នកហើយ,ចូរចុះខែ/ថ្ងៃ/ឆ្នាំ នៅត្រង់បន្ទាត់ខែ/ថ្ងៃ/ឆ្នាំ,សរសេរឈ្មោះក្រុងដែលអ្នកបានបំពេញក្រដាសនេះ ។ ចូរចុះហត្ថលេខាលើក្រដាសពាក្យនោះ ។

ចុងចោទអាចត្រូវការត្រូវជួយផ្តល់ ឯកសារឲ្យអ្នក សំរាប់ឆ្លើយទៅនិងបដ្ឋទាលិខិតនេះ ។ អ្នកមានសិទ្ធិរក្សាអាសយដ្ឋានរស់នៅ ជាអាថិកំបាំង ។ បើអ្នកមានអាសយដ្ឋានមួយ,ក្រៅពីទីលំនៅរបស់អ្នក, ចូរផ្តល់អាសយដ្ឋាននេះជាកន្លែងដែលអាចទទួលឯកសារផ្លូវច្បាប់របស់អ្នក ។

# តំណាង

| តុលាការវិវាសុំទោន សំរាប់ | |
|---|---|
| បណ្តឹងទាជន<br>vs.<br>ជនឆ្លើយតប | លេខ:<br>**បណ្តឹងទាលិខិតស្នើសុំដីកាបញ្ជា សំរាប់ការពារ**<br>(PTORPRT) (គ្រប់សំណុំរឿង) |

| | |
|---|---|
| 1. ☐ខ្ញុំ ☐ សមាជិកគ្រួសារខ្ញុំ ឬសមាជិកគ្រួសារ ជាជនរងគ្រោះដោយហិង្សាគ្រួសារ ដោយចុងចោទ បានធ្វើ ដូចមានរៀបរាប់នៅត្រង់សេចក្តីថ្លែងខាងក្រោម ។ | 3. ខ្ញុំអាយុ:<br>☐ ក្រោម១៦ឆ្នាំ ☐ ១៦ ឬ ១៧ឆ្នាំ ☐ ១៨ឆ្នាំ ឡើងទៅ<br>អាយុរបស់ជនឆ្លើយតប:<br>☐ ក្រោម១៦ឆ្នាំ ☐ ១៦ ឬ ១៧ឆ្នាំ ☐ ១៨ឆ្នាំ ឡើងទៅ |
| 2. ☐ ខ្ញុំរស់នៅក្នុងខោនធីនេះ ។<br>☐ ខ្ញុំបានចេញពីទីលំនៅរបស់ខ្ញុំ ដោយសារការធ្វើទុក្ខទោស ហើយនេះជាខោនធីនៃទីលំនៅថ្មី ឬទីលំនៅពីមុនរបស់ខ្ញុំ ។ | |

4. ទំនាក់ទំនងរបស់ខ្ញុំទៅនិងជនឆ្លើយតបគឺ
- ☐ ប្តី-ប្រពន្ធ
- ☐ ប្តី-ប្រពន្ធពីដើម
- ☐ ឪពុកម្តាយឬកូន
- ☐ ប្រសារ
- ☐ សាច់ឈាមជាប់គ្នា
- ☐ មានកូនជាមួយគ្នា
- ☐ រស់នៅជាមួយគ្នាសព្វថ្ងៃ
- ☐ នៅជាមួយគ្នាពីមុន
- ☐ ដើរលេងជាមួយគ្នាសព្វថ្ងៃនេះ
- ☐ បានដើរលេងជាមួយគ្នាពីមុន

5. អត្តសញ្ញាណប័ណ្ណនៃក្មេងក្រោមអាយុ(បើមាន) ☐ មិនមានក្មេងក្រោមអាយុចូលរួមទេ ។

| ឈ្មោះ<br>ឈ្មោះខ្លួន,កណ្តាល,ដើមអក្សរ,ត្រកូល: | អាយុ | សាសន៍ | ភេទ: | ទំនាក់ទំនងទៅនិង<br>បណ្តឹងទាជន | ចុងចោទ | នៅជាមួយ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

6. សំណុំរឿងតុលាការ,ឬដីកាកំរិតព្រំដែន ពីតុលាការផ្សេងទៀត,ឬដីកាបញ្ជាមិនឲ្យទាក់ទងជាមួយខ្ញុំ,ក្មេងក្រោមអាយុ ហើយ និងជនឆ្លើយតប ។

| | | | |
|---|---|---|---|
| **ឈ្មោះសំណុំរឿង** | | | |
| **លេខសំណុំរឿង** | | | |
| **តុលាការ/ខោនធី** | | | |

**សំណើសុំដីកាបញ្ជាបណ្តោះអាសន្ន:** ភាពអាសន្នបន្ទាន់ មានដូចបានរៀបរាប់នៅត្រង់សេចក្តីថ្លែងខាងក្រោម: ខ្ញុំត្រូវការសុំតុលាការ ចេញដីកាបញ្ជា ដាក់កំរិតជាបណ្តោះអាសន្ន ដោយមិនបាច់ប្រាប់ចុងចោទឲ្យដឹង រហូតដល់សវនាការទើបប្រាប់ទេ, ដើម្បីគេចកុំឲ្យមានគ្រោះថ្នាក់ ដែលមិនអាចកែបាន ។ ខ្ញុំសូមស្នើសុំឲ្យមានដីកាបញ្ជា សំរាប់ការពារ ដែលនឹង:

| | | **ខ្ញុំសូមស្នើ ឲ្យមានដីកាបញ្ជា សំរាប់ការពារ** ក្រោយពីសវនាការ **ដែលនឹង**: |
|---|---|---|
| | | [1] **ដាក់កំរិតហាម**ជនឆ្លើយតប កុំឲ្យធ្វើឲ្យមានទុក្ខទោសដល់រាងកាយ,របួសដល់រាង, វាយតប់,រួមទាំងការរំលោភផ្លូវភេទ, ហើយនិងការព្យាបាទ,ប្រើពាក្យអសុរោះ,គំរាម,ឬឈ្លបចាប់ ☐ ខ្ញុំ ☐ ក្មេងក្រោមអាយុ មានឈ្មោះក្នុងអត្ថបទលេខ៥ខាងលើ ☐ តែក្មេងក្រោមអាយុនេះប៉ុណ្ណោះ: |
| | | [2] **ដាក់កំរិតហាម**ជនឆ្លើយតប កុំឲ្យធ្វើឲ្យមកក្បែរ ហើយនិងកុំឲ្យទាក់ទងអ្វីទាំងអស់, ផ្ទាល់ខ្លួន ឬតាមរយៈជនដទៃ,តាមទូរស័ព្ទ,សំបុត្រ,ឬតាមមធ្យោបាយណាមួយ,ដោយចំពោះ,ឬមិនចំពោះ, លើកលែងតែការផ្ញើឯកសារតុលាការមកឲ្យ,ជាមួយ ☐ ខ្ញុំ ☐ ក្មេងក្រោមអាយុ មានឈ្មោះក្នុងអត្ថបទ លេខ៥ខាងលើ, យល់ព្រមឲ្យសួរសុខទុក្ខតាមដីកាបញ្ជាតុលាការណាមួយ ☐ តែក្មេងក្រោមអាយុនេះប៉ុណ្ណោះ, យលព្រមឲ្យសួរសុខទុក្ខតាមដីកាបញ្ជាតុលាការ: |
| | | [3] **ដក** ជនឆ្លើយតបចេញពី ☐ ទីលំនៅដែលបានចែកគ្នានៅ ☐ ទីលំនៅរបស់ខ្ញុំ ☐ កន្លែងធ្វើការរបស់ខ្ញុំ ☐ សាលារៀនរបស់ខ្ញុំ ☐ កន្លែងមើលក្មេង ឬសាលារៀនទៃ ☐ ក្មេងក្រោមអាយុមានឈ្មោះត្រង់អត្ថបទ លេខ៥ខាងលើ ☐ តែក្មេងក្រោមអាយុនេះប៉ុណ្ណោះ:<br><br>☐ ផ្សេងៗ:<br><br>អ្នកមានសិទ្ធិរក្សាអាសយដ្ឋានទីលំនៅរបស់អ្នក ដោយអាថិកំបាំងបាន ។ |
| | | [4] **ណែនាំ** ជនឆ្លើយតប ឲ្យចេញពីទីលំនៅបានចែកគ្នា ហើយទុកកន្លែងនេះឲ្យខ្ញុំ ។ |
| | | [5] **ហាមឃាត់** ជនឆ្លើយតប កុំឲ្យមកនៅក្នុងរង្វង់ដោយចេតនា,ឬរស់នៅក្នុងរវាង(ចម្ងាយ) : ☐ ទីលំនៅបានចែកគ្នានៅ ☐ ទីលំនៅរបស់ខ្ញុំ ☐ កន្លែងធ្វើការរបស់ខ្ញុំ ☐ សាលារៀនខ្ញុំ ☐ កន្លែងមើលក្មេង ឬសាលារៀនទៃ ☐ ក្មេងក្រោមអាយុមានឈ្មោះត្រង់អត្ថបទលេខ៥ខាងលើ ។<br>☐ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ:<br><br>☐ ផ្សេងៗ: |

| | | |
|---|---|---|
| | | 6 **ប្រគល់** ឲ្យខ្ញុំ នូវរបស់របរ ដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនពិសេសៗរបស់ខ្ញុំ រួមបញ្ចូលទាំងអស់ដូចតទៅ: |
| | | 7 ប្រគល់ ឲ្យខ្ញុំ ប្រើប្រាស់រថយន្តដូចតទៅនេះ:<br>ឆ្នាំ,ម៉ាក,ម៉ូដែល ________________________ ,លេខឡាន ______________ |
| | | 8 **ផ្សេងៗ:** |
| | | 9 **ណែនាំ** ចុងចោទ ឲ្យចូលរួមក្នុងការព្យាបាល ឬឱវាទណែនាំដែលសមរម្យ ។ |
| | | 10 **តម្រូវ** ឲ្យចុងចោទ ចេញថ្លៃឈ្នួលផ្សេងៗ ហើយនិងតម្លៃនៃសកម្មភាពនេះ ។ |
| | | 11 **ត្រូវមានប្រសិទ្ធិភាពប្រើ** បានអស់រយៈជាងមួយឆ្នាំ ពីព្រោះជនឆ្លើយតប ប្រាកដជានៅបន្តប្រើហឹង្សាគ្រួសារ ទល់និងខ្ញុំ បើសិនជាដីកាបញ្ជាត្រូវផុតអាណត្តិ ក្នុងរយៈពេលមួយឆ្នាំ ។ |
| ចូរគូសដូចតទៅនេះ បើអ្នកស្នើសុំកិច្ចការពារ តែក្មេងក្រោមអាយុប៉ុណ្ណោះ: | | |
| | | 12 ការសួរសុខទុក្ខណាមួយត្រូវឲ្យស្របតាមដីកាបញ្ជាតុលាការ,**ប្រគល់**ការមើលថែរក្សាឲ្យខ្ញុំ,ឲ្យខ្ញុំគ្រប់គ្រង ហើយនិងត្រួតត្រា ☐ ក្មេងក្រោមអាយុមានឈ្មោះត្រង់អត្ថបទលេខ៥ខាងលើ ☐ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ ។ |
| | | 13 **ដាក់កំរិតហាម** ចុងចោទ កុំឲ្យជ្រៀតជ្រែក ក្នុងកិច្ចអាណាព្យាបាល រាងកាយឬផ្លូវច្បាប់នៃ ☐ ក្មេងក្រោមអាយុមានឈ្មោះត្រង់អត្ថបទលេខ៥ខាងលើ ☐ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ: |
| | | 14 **ដាក់កំរិតហាម** ជនឆ្លើយតប កុំឲ្យដកចេញពីរដ្ឋនូវ ☐ ក្មេងក្រោមអាយុមានឈ្មោះត្រង់អត្ថបទលេខ៥ខាងលើ ☐ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ: |

**សំណើសុំជំនួយពិសេស ពីទីភ្នាក់ងារមានសមត្ថកិច្ច:**

ខ្ញុំស្នើសុំឲ្យតុលាការចេញបញ្ជា ទៅឲ្យទីភ្នាក់ងារមានសមត្ថកិច្ច ដើម្បីជួយខ្ញុំឲ្យបាន:

- ☐ ទីលំនៅរបស់ខ្ញុំវិញ ។ ☐ ប្រើប្រាស់រថយន្តដែលបានកំណត់ឲ្យ;
- ☐ វត្ថុជាកម្មសិទ្ធិចាំបាច់ផ្ទាល់របស់ខ្ញុំ នៅនិង ☐ ទីលំនៅដែលបានចែកគ្នានៅ ☐ ទីលំនៅរបស់ជនឆ្លើយតប ☐ ផ្សេងៗ ។
- ☐ គ្រប់គ្រងនូវ ☐ ក្មេងក្រោមអាយុមានឈ្មោះត្រង់អត្ថបទលេខ៥ខាងលើ ☐ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ (បើសិនជាអនុវត្តបាន
  ______________________________________________
  ______________________________________________.
- ☐ ផ្សេងៗ: ______________________________________.

ហឹង្សាគ្រួសារ រួមទាំងការធ្វើឲ្យមានទុក្ខទោសរាងកាយ,របួសខ្លួនប្រាណ,ការវាយតប់,ឈ្លបចាប់,ឬការគំរាមថាធ្វើទុក្ខទោសរាងកាយដោយចៀសមិនរួច,របួសខ្លួនប្រាណ,ការវាយតប់ រវាងគ្រួសារ ឬសមាជិកគ្រួសារ ។

**សេចក្តីថ្លែង:** ជនឆ្លើយតប បានប្រព្រឹត្តបំពានហឹង្សាគ្រួសារ តាមលក្ខណ:ដូចតទៅ ។ (ចូររៀបរាប់ សកម្មភាពជាក់លាក់ នៃហឹង្សាគ្រួសារ ហើយនិង ខែ/ថ្ងៃ/ឆ្នាំសមរម្យ,ចាប់ផ្តើមអំពីថ្មីៗ ។ អ្នកប្រហែលជាត្រូវការចម្លើយពីប៉ូលីសផង) ។
ចូររៀបរាប់ឧប្បត្តិហេតុពេលថ្មីៗនេះ ឬការគំរាមកំហែង ផ្នែកហឹង្សា ហើយនិងខែ/ថ្ងៃ/ឆ្នាំ: ______________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

ចូររៀបរាប់ឧប្បត្តិហេតុពេលកន្លងទៅ ដែលអ្នកមានការពិសោធន៍ផ្នែកហឹង្សា,កន្លែងដែលអ្នកខ្វាចមានរបួស,ឬកន្លែងដែលជនឆ្លើយតប បានគំរាមកំហែងថាធ្វើទុក្ខទោស ឬក៏ចង់សម្លាប់អ្នក : ______________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

ចូររៀបរាប់ហឹង្សា ឬការគំរាមកំហែងណាមួយទៅលើក្មេង: ______________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

ចូររៀបរាប់ការព្យាបាលផ្នែកពេទ្យ ដែលអ្នកបានទទួល ហើយនិងសំរាបអ្វី:

ចូររៀបរាប់ការគំរាមថា នឹងសម្លាប់ខ្លួន ឬឥរិយាបថសម្លាប់ខ្លួនដោយជនឆ្លើយតប:

តើជនឆ្លើយតបមានកាំភ្លើងប្រើឬទេ? ☐ បាទ/ចាស ☐ ទេ

តើជនឆ្លើយតប ប្រើកាំភ្លើង,សស្ត្រាវុធ,ឬរបស់ទាទា សំរាប់គំរាម ឬធ្វើទុក្ខទោសដល់អ្នកដែរឬទេ? សូមរៀបរាប់:

បើអ្នកស្នើសុំឲ្យតុលាការចេញដីកាបញ្ជាការពារ យូរជាងរយៈមួយឆ្នាំ,ចូររៀបរាប់នូវមូលហេតុនេះ ថាមកពីអ្វី:

ផ្សេងៗ:

(ចូរប្រើក្រដាសផ្សេង ប្រសិនបើចាំបាច់)

ចូរគូសប្រអប់នេះ បើមានប្រើសារធាតុចូលផង: ☐ សុរា ☐ គ្រឿងញៀនដែលហាមឃាត់ ☐ ផ្សេងៗ

ខ្ញុំសូមទទួលខុសត្រូវចំពោះការភូតភរកុហក់របស់ខ្ញុំ នៅក្រោមច្បាប់រដ្ឋវ៉ាស៊ិនតោន ថាពត៌មាននេះគឺពិត ហើយត្រឹមត្រូវ ។

បានចុះនៅ ____________ នៅ ________________________ វ៉ាស៊ិនតោន ។

______________________

ហត្ថលេខាបដ្ឋនាការជន

អ្នកមានសិទ្ធិរក្សាអាសយដ្ឋានទីលំនៅរបស់អ្នក ជាអាថ៌កំបាំងបាន ។ បើអ្នកមានអាសយដ្ឋានមួយ,ចូរផ្តល់ក្រៅពីអាសយដ្ឋានរបស់អ្នក, សូមផ្តល់អាសយដ្ឋាននេះ ជាកន្លែងដែលអ្នក អាចទទួល ឯកសារខាងផ្លូវច្បាប់: